01058704

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 28 / 01 / 2015
ម៉ោង (Time/Heure): 14:40
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada

E319/9

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៥

**ជូនចំពោះ÷** ចៅក្រម **Mark B. Harmon**
សហចៅក្រមស៊ើបអង្កេតអន្តរជាតិ

**ពី÷** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន÷** លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង
ភាគីទាំងអស់ មេធាវីប្រចាំការសម្រាប់ ខៀវ សំផន

**កម្មវត្ថុ÷** សំណើសុំដាក់បង្ហាញបទសម្ភាសន៍សម្ងាត់ក្នុងសំណុំរឿង004 ដល់មេធាវីប្រចាំការ

១. នៅថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញសេចក្តីសម្រេច អនុញ្ញាតឱ្យសហព្រះរាជអាជ្ញាដាក់បង្ហាញកំណត់ហេតុនៃការស្តាប់ចម្លើយចំនួន ២៦ ដែលជាឯកសារសម្ងាត់ពីសំណុំរឿង ០០៤ ដល់អង្គជំនុំជម្រះសាលាដំបូង មេធាវីការពារក្តីជនជាប់-ចោទទាំងពីរ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ E319.2 កថាខណ្ឌ ២៣) នៅក្នុងសំណុំរឿង០០២។ ការអនុញ្ញាតនេះហាមមិនឱ្យដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយដែលជាឯកសារសម្ងាត់ទាំង ២៦ នេះ ទៅកាន់ជនណាម្នាក់ដែលមិនមានកំណត់ច្បាស់លាស់នៅក្នុងសេចក្តីសម្រេចនេះឡើយ (ឯកសារ E319.2 កថាខណ្ឌ ២៣)។

២. នៅថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ទៅអង្គភាពគាំពារការការពារក្តីឱ្យតែងតាំងមេធាវីប្រចាំការរបស់តុលាការសម្រាប់ ខៀវ សំផន (ឯកសារ E321/2)។ បន្ទាប់មក មេធាវីប្រចាំការក៏ត្រូវបានតែងតាំង ហើយបានបង្ហាញខ្លួននៅក្នុងតុលាការជាលើក

ដំបូងនៅថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៥។ មេធាវីប្រចាំការមានភារកិច្ចក្នុងការរៀបចំខ្លួន ដើម្បីមានលទ្ធភាពគ្រប់គ្រាន់ក្នុងការជំនួសតួនាទីមេធាវីការពារក្តី ខៀវ សំផន នៅគ្រប់ពេលវេលាទាំងអស់ ប្រសិនបើអង្គជំនុំជម្រះយល់ឃើញថា មានភាពចាំបាច់ក្នុងការជំនួសមេធាវីការពារក្តីបច្ចុប្បន្នរបស់ ខៀវ សំផន (ឯកសារ E321/2 កថាខណ្ឌ ១៩, *សូមមើលផងដែរឯកសារ* E321/2/2)។

៣. ហេតុដូច្នេះ អង្គជំនុំជម្រះស្នើសុំសហចៅក្រមស៊ើបអង្កេតអន្តរជាតិពង្រីកវិសាលភាពនៃការអនុញ្ញាតដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយដូចមានចែងនៅក្នុងឯកសារ E319.2 ជូនដល់មេធាវីប្រចាំការ ក្រោមលក្ខខណ្ឌដូចគ្នាទៅនឹងភាគីដទៃទៀតដែរ។ អង្គជំនុំជម្រះក៏ស្នើឱ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិ អនុញ្ញាតឱ្យមេធាវីប្រចាំការទទួលបាននូវការដាក់បង្ហាញឯកសារសម្ងាត់នានានៅពេលអនាគតផងដែរ ចំពោះឯកសារពីការស៊ើបអង្កេតដែលកំពុងប្រព្រឹត្តទៅនាពេលបច្ចុប្បន្ននេះ។